01658567

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

D267/33

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៥)

<u>អង្គបុរេជំនុំជម្រះ</u>

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម នី យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 11 / 2020
ម៉ោង (Time/Heure) : 13:43
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

សារណា:

## សេចក្តីសម្រេចលើសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់ ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

<u>សហព្រះរាជអាជ្ញា:</u>

ជា លាង
Brenda J. HOLLIS

<u>សហមេធាវីការពារក្តី យឹម ទិត្យៈ</u>

អាង ឧត្តម
Michael G. KARNAVAS

<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី</u>

ហុង គីមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉េន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN- NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ" ("សារណាបន្ថែម")[1] ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញ "ដីកាដំណោះស្រាយ" របស់ខ្លួនដោយចោទប្រកាន់បញ្ជូន មាស មុត ទៅជំនុំជម្រះ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[2] ហើយសហចៅក្រមស៊ើបអង្កេតជាតិ បានចេញ "ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត" ("ដីកាសម្រេចលើកលែងចោទប្រកាន់")[3] (ជារួមហៅថា "ដីកាដំណោះស្រាយ")។ ដីកាដំណោះស្រាយត្រូវបានដាក់តែជាភាសាអង់គ្លេស និងជាភាសាខ្មែរដាច់ដោយឡែកពីគ្នា ហើយសំណៅបកប្រែបានដាក់ជូនតាមក្រោយ។

2. នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិ បានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[4] ជាភាសាខ្មែរ។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ សហមេធាវីការពារក្តី មាស មុត ("សហមេធាវី") និងសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[5] និងដីកាសម្រេចលើកលែងចោទប្រកាន់[6] ជាភាសាអង់គ្លេស។

---

[1] សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣"), សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ ឯកសារ D267/27 ("សារណាបន្ថែម (ឯកសារ D267/27)")។

[2] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267។

[3] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266។

[4] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/3 ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3)")។

[5] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿង ទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត (ឯកសារ D267/4)")។

3. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ("សេចក្តីពិចារណា") ក្នុងសំណុំរឿង ០០៤/២[7]។

4. នៅថ្ងៃទី១២ ខែ មីនា ឆ្នាំ២០២០ សហចៅក្រមអន្តរជាតិ នៃអង្គបុរេជំនុំជម្រះ បានផ្សព្វផ្សាយដល់ភាគីនានា ដោយចម្លងជូនអង្គបុរេជំនុំជម្រះ ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង និងប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល នូវអនុស្សរណៈអន្តរការិយាល័យ របស់ចៅក្រមអន្តរជាតិ រួមជាមួយឧបសម្ព័ន្ធភ្ជាប់ ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅក្នុងអង្គជំនុំជម្រះ បន្ទាប់ពីការចេញសេចក្តីពិចារណា ក្នុងសំណុំរឿង ០០៤/២ ដោយគូសបញ្ជាក់ថា អង្គបុរេជំនុំជម្រះបានចាត់វាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង[8]។

5. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រធានអង្គបុរេជំនុំជម្រះ បានចេញអនុស្សរណៈអន្តរការិយាល័យអះអាងថា មានតែផ្នែកនៃសេចក្តីពិចារណាដែលបានសម្រេចជាឯកច្ឆន្ទប៉ុណ្ណោះ ដែលមានអានុភាព
អនុវត្ត[9]។

6. នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ សហមេធាវីបានដាក់ "សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ

---

[6] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងទៅនឹងដីកាសម្រេច លើកលែងចោទប្រកាន់ មាស មុត (D266), ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2 ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2)")។

[7] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") (PTC60), សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33)")។

[8] សំណុំរឿង ០០៤/២ អនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រមអន្តរជាតិ Kang Jin BAIK និងOlivier BEAUVALLET ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/36 និង D360/45។

[9] សំណុំរឿង ០០៤/២ អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/37 និង D360/46។

ក្នុងរឿងក្តី ០០៤/២" ("សំណើសុំការបញ្ជាក់បំភ្លឺ") ដោយស្នើសុំឲ្យអង្គបុរេជំនុំជម្រះ (១) សម្រេចទទួលយកសំណើ និង (២) ផ្តល់ការបញ្ជាក់បំភ្លឺតាមការស្នើសុំ ពាក់ព័ន្ធនឹងសេចក្តីពិចារណារបស់អង្គជំនុំជម្រះ[10]។

7. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីថ្លែងការណ៍រួមជាសាធារណៈ ពាក់ព័ន្ធសំណុំរឿង ០០៤/២ ដោយបញ្ជាក់ថា អង្គជំនុំជម្រះ មិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤/២ ឡើយ បើគ្មានការជូនដំណឹង និងការបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូង ("សេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង")[11]។ ទោះបីចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ទទ្បីករណ៍អាចលើកឡើងបានក្នុងកាលៈទេសៈពិសេសទាំងនេះថា អង្គជំនុំជម្រះសាលាដំបូងមាន "សិទ្ធិអំណាចពិសេស" ក្នុងការដោះស្រាយបញ្ហាមួយចំនួនក្តី តែចៅក្រមជាតិបានថ្លែងថា បញ្ហានានាត្រូវបានបិទបញ្ចប់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយថា "នឹងពុំមានការជំនុំជម្រះក្តីលើសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន នៅពេលនេះ ឬនៅពេលអនាគតឡើយ"[12]។

8. នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ សហមេធាវីបានដាក់សារណាបន្ថែម ស្នើសុំដល់អង្គបុរេជំនុំជម្រះ (១) សម្រេចថាសារណាបន្ថែមនេះ អាចទទួលយកបាន (២) ប្រកាសថា ដីកាដំណោះស្រាយក្នុងរឿងក្តី ០០៣ ត្រូវទុកជាមោឃៈ និងឥតបានការ និង (៣) ផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ក្នុងរឿងក្តី ០០៣។[13] បន្ថែមពីនេះ ពួកគេបានស្នើរសុំអោយអង្គបុរេជំនុំជម្រះធ្វើការស្តាប់សវនាការអំពីការលើកឡើងនៅសំណើរ និងបញ្ហាសំខាន់ៗ ដែលស្មុគស្មាញ [14]។

---

[10] សំណុំរឿង ០០៣ សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺ លើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ឯកសារ D266/19 និង D267/24 ("សំណើសុំការបញ្ជាក់បំភ្លឺ (ឯកសារ D266/19 និង D267/24)")។

[11] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍របស់ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន" ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ("សេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង")។

[12] សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង។

[13] សារណាបន្ថែម (ឯកសារ D267/27)

[14] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ១

9. នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ អង្គបុរេជំនុំជម្រះបានជូនដំណឹង ដល់ភាគីក្នុងសំណុំរឿង ០០៣ តាមរយៈសារអេឡិចត្រូនិកថា អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាម "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យាពេលឆ្លើយតបទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ" ដែលបានដាក់នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ហើយពន្យាកាលបរិច្ឆេទកំណត់ សម្រាប់ការដាក់ចម្លើយតបរបស់គាត់ រហូតដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០[15]។

10. នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ "ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ" ដោយស្នើដល់អង្គបុរេជំនុំជម្រះ ច្រានចោលសារណាបន្ថែមទាំងមូល។[16]

11. នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ សហមេធាវីបានដាក់ "ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើប

---

[15] សារអេឡិចត្រូនិកពីក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ផ្ញើរជូនភាគីនានា អំពីសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបន្ថែមពេលវេលា ក្នុងការឆ្លើយតបចំពោះសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ម៉ោង ២ និង៥៩នាទីរសៀល។ *សូមមើលផងដែរ* សំណុំរឿង ០០៣, សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យាពេលឆ្លើយតបទៅនឹង សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ឯកសារ D267/28។

[16] សំណុំរឿង ០០៣, ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ឯកសារ D267/29 ("ចម្លើយតប (ឯកសារ D267/29)")



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ"[17]។

12. នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ អង្គជំនុំជម្រះតុលាការកំពូលបានចេញ "សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង" ("សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២") ដោយបដិសេធអង្គសេចក្ដីនៃបណ្ដឹងសាទុក្ខភ្លាមៗ ដែលបានដាក់នៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២០[18] និងបានបិទបញ្ចប់សំណុំរឿង ០០៤/២[19]។

## II. សារណា

13. នៅក្នុងសារណាបន្ថែមរបស់ពួកគេ សហមេធាវីបានស្នើដល់អង្គបុរេជំនុំជម្រះ (១) សម្រេចថាសារណាបន្ថែមអាចទទួលយកបាន[20] (២) ប្រកាសថាដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ មោឃៈនិងឥតបានការ[21] និង (៣) ផ្អាកជាអចិន្ត្រៃយ៍កិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៣[22]
។

[17] សំណុំរឿង ០០៣, ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D267/31 ("ការឆ្លើយតប (ឯកសារ D267/31)")។

[18] សំណុំរឿង ០០៤/២ បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០, ឯកសារ E004/2/1 ("បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿង ០០៤/២ (E004/2/1)")។

[19] សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០, ឯកសារ E004/2/1/1/2 ("សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ ក្នុងសំណុំរឿង ០០៤/២ (E004/2/1/1/2)")។

[20] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ១-៣, ៥២។

[21] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ២៥-៣២, ៥១-៥២។

[22] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ២៥, ៣៣-៤៩, ៥១-៥២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

14. សហមេធាវីបានលើកឡើងថា សារណាបន្ថែមអាចទទួលយកបាន ព្រោះ (១) សេចក្តីថ្លែងការណ៍របស់ អង្គជំនុំជម្រះសាលាដំបូង បង្កើតបានជាព័ត៌មានដែលរកឃើញថ្មី ដែលស្រដៀងនឹងភស្តុតាងដែលរកឃើញថ្មី អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលអាចត្រូវបានទទួលយក និងយកមកពិចារណា ប្រសិនបើអាចនាំទៅដល់ការស្វែងរកការពិត ហើយដែលមិនមាន ឬមិនអាចត្រូវបានរកឃើញ ទោះបីជាមានការប្រឹងប្រែងសមស្របក្តី[23] (២) ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ជាពិសេសមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ២១ និងវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង គាំទ្រដល់ការទទួលយកសារណាបន្ថែម ដើម្បីការពារសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងដំណើរការដោយឆាប់រហ័ស ដែលត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញ[24] និង (៣) គឺជាការចាំបាច់ដោយសារតែតម្រូវការចាំបាច់ ក្នុងការធានានូវកិច្ចការរដ្ឋបាលតុលាការដែលល្អ និងយុត្តិធម៌ ដែលអង្គបុរេជំនុំជម្រះ ត្រូវប្រើប្រាស់សិទ្ធិអំណាចដែលមានស្រាប់របស់ខ្លួន "ដើម្បីសម្រេចលើបញ្ហាបន្ទាប់បន្សំ ដែលកើតឡើងដោយសារតែផលវិបាកផ្ទាល់ នៃនីតិវិធីដែលត្រូវបានប្តឹងមកខ្លួន ដោយផ្តល់សំអាងហេតុថា បញ្ហានោះស្ថិតក្រោម

---

[23] សារណាបន្ថែម (ឯកសារ D267/27)កថាខណ្ឌ ១ យោងទៅរកសំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/អជសដ សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ឯកសារ E190 កថាខណ្ឌ ២២ - ២៣។

[24] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ២ *យោងទៅរក កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦* 999 U.N.T.S. 171 និង1057 U.N.T.S. 407 *ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ មាត្រា ១៤-១៥, ច្បាប់ស្តីពីការបង្កើតឱ្យមាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ (នស/រកម/១០០៤/០០៦) ធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") មាត្រា ៣៥ ថ្មី *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ *ចូលជាធរមាននៅ* ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ("កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក") មាត្រា ១២-១៣, *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* (ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣) ("រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣") មាត្រា ៣១។



ECCC * CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

យុត្តាធិការបឋមរបស់ខ្លួន" នៅពេលដែលបទប្បញ្ញត្តិច្បាប់ពុំចែងច្បាស់ ឬយោងទៅលើសិទ្ធិអំណាច ក្នុងការសម្រេចលើបញ្ហាមួយ[25]។

15. ចំពោះអង្គសេចក្តីវិញ ជាបឋម សហមេធាវីបានលើកឡើងថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ គឺមោឃៈ ឥតបានការ និងផុតពីការត្រួតពិនិត្យតាមផ្លូវតុលាការ[26]។ ដើម្បីគាំទ្រដល់ចំណុចនេះ សហមេធាវីបានលើកទឡ្ហីករណ៍ថា សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានកិច្ចការពារដោយស្មើភាពគ្នា ដែលជាសិទ្ធិត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ នឹងត្រូវទទួលរងការរំលោភបំពាន លើកលែងតែការសម្រេចជាឯកច្ឆន្ទ របស់អង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ដែលថាការចេញដីកាដំណោះស្រាយផ្ទុយគ្នា គឺ "ខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក" ត្រូវអនុវត្តផងដែរចំពោះសំណុំរឿង ០០៣ ហើយផលវិបាកនៃការប្រកាសនេះគឺថាៈ ដីកាដំណោះស្រាយដែលខុសច្បាប់ទាំងឡាយ ក្នុងរឿងក្តី ០០៣ គឺត្រូវចាត់ទុកជាមោឃៈ និងឥតបានការ ហើយផុតពីការត្រួតពិនិត្យតាមផ្លូវតុលាការ លើអង្គសេចក្តី[27]។ សហមេធាវីជំទាស់ថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ គឺមានវិការៈនីតិវិធី ដោយសារតែដីកាដំណោះស្រាយនេះ ធ្វើឡើងហួសពីសមត្ថកិច្ច ដោយរំលោភបំពានទៅលើវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង[28]។ ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេច ទោះបីជាវិធាន៧៦ នៃវិធានផ្ទៃក្នុង ដែលគ្រប់គ្រងលើនីតិវិធីមោឃភាព មិនបានចែងអំពីការដាក់សំណើសុំមោឃភាព ក្រោយពេលចេញដីកាដំណោះស្រាយ ហើយមិនមានវិធានណាមួយ នៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក បានប្រមើលទុកជាមុន នូវការធ្វើមោឃភាពដីកាដំណោះស្រាយក្តី តែសហមេធាវីបានអះអាងថា ចន្លោះប្រហោងដែលមាននៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធដីកាដំណោះស្រាយ ដែល

---

[25] សារណាបន្ថែម (ឯកសារ D267/27)កថាខណ្ឌ ៣ *យោងទៅរក* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/អជសដ/អជតក (២៦) សេចក្តីសម្រេចលើសំណើ របស់សហព្រះរាជអាជ្ញា សុំការបញ្ជាក់បំភ្លឺ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ E284/2/1/2 កថាខណ្ឌ ១២, សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និងD360/33) កថាខណ្ឌ ៥១។

[26] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ២៥-៣២, ៥១។

[27] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ២៦។

[28] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ២៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

បានចេញដោយមិនអនុលោមទៅតាម ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ព្រោះអ្នកតាក់តែងសេចក្ដីព្រាង មិនអាចប្រមើលទុកជាមុនបាន នូវការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ក្នុងពេលជាមួយគ្នា[29]។ ហេតុដូច្នេះ សហមេធាវីអះអាងថា ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក តាមរយៈការបកស្រាយវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង យោងទៅតាមវិធានបកស្រាយនៃប្រព័ន្ធច្បាប់ស៊ីវិល[30] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលនៅជាធរមាន[31] និងវិធាននីតិវិធីដែលបានកំណត់ នៅកម្រិតអន្តរជាតិ[32] តម្រូវថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ដែលត្រូវបានសម្រេចថាមោឃៈ និងឥតបានការ ដោយសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/២ គួរត្រូវបានមោឃភាព និងដកចេញពីក្នុងសំណុំរឿង[33]។

16. សហមេធាវី បានលើកឡើងជាបន្តថា អង្គបុរេជំនុំជម្រះចាំបាច់ត្រូវចេញសេចក្ដីសម្រេចផ្អាកជាអចិន្ត្រៃយ៍ លើកលែងតែចៅក្រមអង្គជំនុំជម្រះ អាចឈានដល់សំអាងហេតុរួម លើការវិវឌ្ឍន៍នៃសំណុំរឿង ០០៣[34]។ ក្នុងន័យនេះ សហមេធាវីអះអាងថា ឧបាស្រ័យជាបទដ្ឋាន បន្ទាប់ពីការធ្វើមោឃភាព គឺមិនមានលក្ខណៈជាក់ស្ដែង ឬមិនអាចធ្វើទៅបាន ដោយសារតែចៅក្រមអង្គបុរេជំនុំ

---

[29] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ២៧-២៨។

[30] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ២៩។

[31] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣០។

[32] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣១ យោងទៅ តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ("តុលាការ ICTY") *រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកដទៃទៀត* IT-95-16, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ Dragan Papic ប្រឆាំងសេចក្ដីសម្រេចបន្តនីតិវិធី ដោយវិធីយកសក្ខីកម្ម, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៤, តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរវ៉ាន់ដា ("តុលាការ ICTR") *រដ្ឋអាជ្ញា តទល់នឹង Ntuyahaga* ICTR-98-40-T សេចក្ដីប្រកាសស្ដីពីចំណុចនៃច្បាប់, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩ កថាខណ្ឌ១៧, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ ៤៧ និង៤៨) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់ សហចៅក្រមស៊ើបអង្កេត លេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 មតិរបស់ចៅក្រម ប្រាក់ គឹមសាន និងចៅក្រម DOWNING កថាខណ្ឌ ១៣។

[33] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣២។

[34] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ២៥ ៣៣-៤៩, ៥១-៥២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

01658576



ជម្រះ មិនមានលទ្ធភាពបំពេញកិច្ចស៊ើបសួររួមគ្នា លើសំណុំរឿង ០០៣ ហើយចេញដីកាដំណោះស្រាយដែលបានកែតម្រូវនោះ[35] ហើយនឹងភាពមិនអាចអនុវត្តបាន និងភាពគ្មានសុភវិនិច្ឆ័យ នៃការបង្វិលត្រឡប់សំណុំរឿង ០០៣ ទៅសហចៅក្រមស៊ើបអង្កេត ដែលនឹងបណ្តាលឱ្យមានការពន្យាពេលមិនសមហេតុផល និងរំលោភបំពានទៅលើសិទ្ធិ ទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ មាស មុត[36]។ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍ក្រោយនេះ សហមេធាវីបានសង្កត់ធ្ងន់ (១) ការពន្យារពេលដែលរំពឹងថាមាន ដែលកើតចេញពីការត្រួតពិនិត្យឡើងវិញ ទៅលើសំណុំរឿងទាំងមូលដែលត្រូវធ្វើឡើងដោយបុគ្គលិកថ្មី របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត បន្ទាប់ពីការតែងតាំងឡើងវិញ នូវសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[37] និងដោយសហចៅក្រមស៊ើបអង្កេតជាតិដែលបានបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន តាំងពីប្រាំមួយឆ្នាំមុនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[38] (២) លទ្ធភាពដែលសហចៅក្រមស៊ើបអង្កេត មិនអាចយល់ស្របជាមួយគ្នា លើលទ្ធផលរួម ក្នុងពេលពិភាក្សាសម្រេចរបស់ពួកគេ ក្នុងការចេញដីកាដំណោះស្រាយថ្មី[39] ព្រមទាំងអលទ្ធភាពរបស់ពួកគាត់ ក្នុងការផ្តល់យុត្តិធម៌ និងចេញដីកាដំណោះស្រាយ ដែលអនុលោមទៅតាម ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[40] និង (៣) លទ្ធភាពដែលថា សវនការជំនុំជម្រះ នឹងត្រូវពន្យាពេល

---

[35] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤១។

[36] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣៤ យោងទៅរក រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៣១, កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១២(១), ១៣(១), ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ ថ្មី ៣៥ ថ្មី (គ), វិធានផ្ទៃក្នុងនៃ អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ វិធាន ២១(៤), កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(គ)។

[37] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣៥។

[38] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣៦ *យោងទៅរក* សំណុំរឿង ០០៣ សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D13 សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំងមាស មុត ថ្ងៃទី10 ខែមករា ឆ្នាំ២០១៧ ឯកសារ D225។

[39] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣៧។

[40] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣៩ *យោងទៅរក* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៣៥-៣៦, ៥៤, ៨៩, ៩៩-១០០, ១២១-១២៤។



E.C.C.C • C.E.T.C • PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

បន្ទាប់ពីមានបណ្ដឹងឧទ្ធរណ៍ដែលមិនអាចជៀសបានរបស់ភាគីនានា ប្រឆាំងដីកាដំណោះស្រាយដែលបានកែសម្រួល[41]។

17. សហមេធាវីបានលើកឡើងករណីបន្ថែមថា មិនមានលទ្ធភាពសម្រាប់ការត្រួតពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ក្នុងការដោះស្រាយការជាប់គាំងផ្នែកនីតិវិធី[42]។ ដើម្បីគាំទ្រចំពោះចំណុចនេះ សហមេធាវីអះអាងថា (១) ដោយសារតែទស្សនៈផ្សេងគ្នា ដែលលើកឡើងដោយចៅក្រមជាតិ និងចៅក្រមអន្តរជាតិ នៃអង្គបុរេជំនុំជម្រះ នៅក្នុងសេចក្ដីពិចារណាក្នុងសំណុំរឿង ០០៤/២ និងនៅពេលបន្តបន្ទាប់ក្រោយមកទៀតនោះ អង្គបុរេជំនុំជម្រះនឹងមិនអាចឈានទៅដល់ ការឯកភាពជាឯកច្ឆន្ទលើបញ្ហាថាតើ ត្រូវបញ្ជូនសំណុំរឿង ០០៣ ដែរឬអត់ទៅអង្គជំនុំជម្រះសាលាដំបូង[43] (២) សេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង បង្ហាញថា ខ្លួនមិនត្រូវបានប្ដឹងឱ្យទទួលយកសំណុំរឿង ០០៣ ឬអាចធ្វើការសម្រេចទៅលើ ផលវិបាកនៃការយល់ខុសគ្នារបស់ អង្គបុរេជំនុំជម្រះលើ បណ្ដឹងឧទ្ធរណ៍ខ្វែងឡើយ[44] (២) អង្គជំនុំជម្រះតុលាការកំពូល បើតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង មិនមានយុត្តាធិការក្នុងការសម្រេចលើបញ្ហា ដែលអង្គជំនុំជម្រះសាលាដំបូង មិនអាចចេញសេចក្ដីសម្រេចជាផ្លូវការនោះឡើយ[45] ហើយបើទោះបីជាអង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាថា ដើម្បីជាប្រយោជន៍យុត្តិធម៌ ត្រូវផ្ដល់ "ការណែនាំផ្លូវច្បាប់ ... អាចចេញពីអង្គភាពណាមួយរបស់តុលាការ" ក៏មិនមានការចង្អុលបង្ហាញណាមួយដែលថា អង្គជំនុំជម្រះតុលាការកំពូល នឹងមិនញែកដាច់គ្នាទៅតាមខ្សែចៅក្រមជាតិ និងចៅក្រមអន្តរជាតិនោះដែរ[46] ហើយសំខាន់ជាងនេះទៀតនោះ គោលការណ៍នៅក្នុងប្រព័ន្ធច្បាប់

---

[41] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣៨។

[42] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤០។

[43] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤០-៤១។

[44] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤១ *យោងទៅ* សេចក្ដីថ្លែងការណ៍របស់ អង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ២។

[45] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤២។

[46] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤៣។

ខំមិនឡ ស្តីពី *ទ្រឹស្តីយុត្តិសាស្ត្រ* ក៏មិនអាចយកមកអនុវត្តបានឡើយ ដូច្នេះហើយ គោលការណ៍គតិយុត្តិណាមួយដែលបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន គឺពុំចងកាតព្វកិច្ចឲ្យអង្គបុរេជំនុំជម្រះគោរពតាម នៅក្នុងការបកស្រាយច្បាប់នោះទេ[47]។

18. ជាចុងក្រោយសហមេធាវី បានលើកឡើងករណីថា ផ្អែកលើការបកស្រាយខាងលើ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចឈានដល់ការចេញសំអាងហេតុរួម លើការវិវឌ្ឍន៍នៃសំណុំរឿង ០០៣ អង្គជំនុំជម្រះគួរពឹងផ្អែកលើសិទ្ធិអំណាចដែលមានស្រាប់របស់ខ្លួន ចេញសេចក្តីសម្រេចផ្អាកជាអចិន្ត្រៃយ៍ទាំងស្រុង លើកិច្ចដំណើរការនីតិវិធី ដើម្បីជៀសវាងពីភាពអយុត្តិធម៌[48]។ ហេតុដូច្នេះ អង្គជំនុំជម្រះគួរប្រើប្រាស់ សិទ្ធិអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការប្រើប្រាស់ទ្រឹស្តីនៃ ដំណើរការរំលោភនីតិវិធី ដើម្បីរារាំងការរំលោភបំពានធ្ងន់ធ្ងរ និងដាក់ស្តែងទៅលើសិទ្ធិ ទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌[49]។ សហមេធាវីអះអាងថា បើគ្មានការផ្អាកជាអចិន្ត្រៃយ៍ កិច្ចដំណើរការនីតិវិធីទេ មាស មុត នឹងសល់តែដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅតាមលងបន្លាចគាត់ជារៀងរហូត ប្រសិនបើដំណើរការនីតិវិធី ត្រូវបានបញ្ឈប់ ហើយនឹងទទួលរងព្យសនកម្ម មិនអាចជួសជុលបាន និងត្រូវបានដកហូតពីគាត់ជាអចិន្ត្រៃយ៍ នូវសិទ្ធិនានារបស់គាត់ ដែលត្រូវបានធានាការពារ ដោយរដ្ឋធម្មនុញ្ញ[50]។ បើទោះបីជាមិនមានបទប្បញ្ញត្តិជាក់ច្បាស់ នៅក្នុងក្របខណ្ឌ អ.វ.ត.ក ដែលប្រមើលទុកមុនអំពី ការផ្អាកកិច្ចដំណើរការនីតិវិធីក្តី[51] សហមេធាវីបានចង្អុលទៅរក ការទទួលស្គាល់របស់ អង្គជំនុំជម្រះតុលាការកំពូលដែលថា កិច្ចដំណើរការនីតិវិធីអាចត្រូវបានផ្អាកនៅ អ.វ.ត.ក ក្នុងកាលៈទេសៈមួយចំនួនតូច ហើយនិងមាត្រា ២៨ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលចែងដោយប្រយោល ពីការផ្អាកជាអចិន្ត្រៃយ៍ កិច្ចដំណើរការនីតិវិធី នៅក្នុងករណីដែលអង្គ

[47] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤៣ *យោងទៅរក* សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹង ជម្លោះប្រដាប់អាវុធ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ឯកសារ D87/2/1.7/1 កថាខណ្ឌ ១៣។

[48] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤៤-៤៦។

[49] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤៤, ៤៩។

[50] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤៥។

[51] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤៧។

ការសហប្រជាជាតិ ដកខ្លួនចេញពីកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងឈប់ផ្តល់ជំនួយដល់ អ.វ.ត.ក ក្នុងករណីដែលតុលាករមិនអាច បំពេញតួនាទីរបស់ខ្លួន ក្នុងលក្ខណៈមួយដែលស្របទៅតាមកិច្ចព្រមព្រៀង[52]។ ការលើកឡើងនៅសំណើរអំពីការបំភ្លឺបញ្ហាផ្សេងៗ ដែលសំខាន់ និង ស្មុគស្មាញ ដែលសហមេធាវីបានស្នើរសុំអោយអង្គបុរេជំនុំជម្រះធ្វើការស្តាប់សវនាការ[53]។

19. នៅក្នុងចម្លើយតបរបស់គាត់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើដល់អង្គបុរេជំនុំជម្រះ សម្រេចបដិសេធសារណាបន្ថែម ព្រោះ (១) សារណាបន្ថែមមិនអាចទទួលយកបាន[54] (២) មិនមានការតម្រូវឲ្យអង្គបុរេជំនុំជម្រះ ធ្វើការបដិសេធដីកាដំណោះស្រាយទាំងពីរ របស់សំណុំរឿង ០០៣ ថាមោឃៈ និងឥតបានការ[55] (៣) ភាពជាប់គាំងផ្នែកនីតិវិធី ក្នុងសំណុំរឿង០០៣ មិនមែនមិនអាចជៀសបាននោះឡើយ[56] និង (៤) មិនមានការតម្រូវឲ្យមានការផ្អាកអចិន្ត្រៃយ៍ កិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៣ ទេ[57]។

20. ចំពោះភាពអាចទទួលយកបាននៃសារណាបន្ថែម សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថាសារណាបន្ថែមមិនអាចទទួលយកបាន ដោយសារតែមានភាពយឺតយ៉ាវ និងមិនមានមូលដ្ឋានច្បាស់លាស់[58]។ នៅពេលដំបូង សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា សារណាបន្ថែមគឺជា ការព្យាយាមដោយខុសច្បាប់ ក្នុងការបើកឡើងវិញនូវកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៣ ព្រោះវិធានផ្ទៃក្នុងមិនបានចែង អំពីទឡ្ហីករណ៍បន្ថែមណាមួយ របស់ភាគីនានា នៅក្នុងដំណាក់កាលនេះ ក្នុងកិច្ចដំណើរការនីតិវិធីឡើយ ក្នុងករណីដែលសេចក្តីសន្និដ្ឋាន ជាលាយលក្ខណ៍

---

[52] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៤៧ *យោងទៅរក* សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E138/1/10/1/5/7 កថាខណ្ឌ ៣៨។

[53] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ១

[54] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៣-២១។

[55] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២២-២៦។

[56] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៧-៣១។

[57] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ៣២-៣៧។

[58] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១, ១៣។

អក្សរ លើបណ្ដឹងឧទ្ធរណ៍ បានបញ្ចប់សព្វគ្រប់ សវនាការផ្ទាល់មាត់បានកើតឡើង ហើយអង្គបុរេជំនុំជម្រះបានសម្រាកដើម្បីពិភាក្សាសម្រេច[59]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងថា ភាគីត្រូវបានហាមឃាត់មិនឱ្យដាក់សារណាបន្ថែមទៀត រួមទាំងបណ្ដឹងឧទ្ធរណ៍បន្ថែម លើកលែងតែអង្គបុរេជំនុំជម្រះ ស្នើសុំសារណារបស់ភាគីនានា លើបញ្ហាបន្ថែមណាមួយទៀត[60]។

21. ចំពោះការពឹងផ្អែកដោយខុស របស់សហមេធាវី ទៅលើសេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងនោះ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ជាដំបូងថា សេចក្ដីថ្លែងការណ៍នេះ មិនអាចចាត់ទុកថាជាព័ត៌មានដែលរកឃើញថ្មី ដែលស្រដៀងនឹងភស្តុតាងដែលរកឃើញថ្មីតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ព្រោះគោលបំណងនៃវិធាននោះ គឺអនុញ្ញាតឱ្យមានការទទួលយកភស្តុតាងនៅដំណាក់កាលជំនុំជម្រះ ដែល "អាចនាំទៅដល់ការស្វែងរកការពិត" គឺមិនមែនដើម្បីអនុញ្ញាតឱ្យភាគីនានា ដាក់សារណាជាច្រើន នៅរាល់ពេលដែលមានការអះអាងពីការវិវឌ្ឍន៍ពាក់ព័ន្ធនានា ដែលបានកើតឡើងនៅក្នុងសំណុំរឿងដទៃឡើយ[61]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដោយពិចារណាទៅលើភាពស្មុគ្រស្មាញ និងទំហំនៃសំណុំរឿងនៅ អ.វ.ត.ក ការអនុញ្ញាតឱ្យភាគីដាក់សារណាបន្ថែម នៅរាល់ពេលដែលមានលេចឡើង នូវយុត្តិសាស្ត្រថ្មី ឬការវិវឌ្ឍន៍ផ្នែកនីតិវិធីដទៃទៀត ដែលកើតឡើងនៅតុលាការ ឬនៅតុលាការអន្តរជាតិដទៃទៀត គឺជាការផ្ទុយទៅនឹងផលប្រយោជន៍យុត្តិធម៌ ហើយនិងសិទ្ធិរបស់ មាស មុត ក្នុងការទទួលបាន កិច្ចដំណើរការនីតិវិធីដោយឆាប់រហ័ស[62]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងបន្ថែមថា ការយោងរបស់សហមេធាវី ទៅលើសេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាចេតនាមួយក្នុងការបង្វែងដានអង្គបុរេជំនុំជម្រះ ពីការដែលពួកគេមិនបានដាក់សារណាបន្ថែមរហូតដល់ពេលជាងបួនខែក្រោយ អង្គបុរេជំនុំជម្រះ បានចេញនូវសេចក្ដីពិចារណា ក្នុងសំណុំរឿង ០០៤/២ ដោយសារតែសារណាដែលបានលើកឡើង នៅក្នុងសារណាបន្ថែម មិនមែនកើតឡើង

[59] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៣។

[60] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៣។

[61] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៤។

[62] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ដោយផ្ទាល់ ពី សេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ប៉ុន្តែកើតឡើងពីសេចក្ដីពិចារណាទៅវិញ[63]។

22. ចំពោះបញ្ហាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ មាស មុត សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា សហមេធាវីមិនអាចផ្ដល់ភស្តុតាងគាំទ្រ ដល់ការអះអាងរបស់ពួកគេ ចំពោះចំណុចនេះឡើយ ដោយសារតែអង្គបុរេជំនុំជម្រះ មានសិទ្ធិចូលពិនិត្យ និងមានសមត្ថភាពវិភាគទៅលើការវិវឌ្ឍន៍ពាក់ព័ន្ធនានា នៅក្នុងសំណុំរឿង ០០៤/២ ហើយសិទ្ធិរបស់ មាស មុត ត្រូវបានការពារ ដូចដែលសហមេធាវី បានលើកទឡ្ហីករណ៍ពីសារសំខាន់ នៃបញ្ហាដែលជាចំណុចស្នូលនៃសារណាបន្ថែម តាមរយៈសារណាជាលាយលក្ខណ៍អក្សរ និងសារណាផ្ទាល់មាត់ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៣[64]។

23. ពាក់ព័ន្ធនឹងការអះអាងរបស់សហមេធាវីដែលថា សេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យមានការផ្អាកជាអចិន្ត្រៃយ៍ ទៅលើសំណុំរឿង ០០៣ លើកលែងតែចៅក្រមអង្គបុរេជំនុំជម្រះ អាចឈានដល់ការឯកភាពជាឯកច្ឆន្ទនោះ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា ការអះអាងរបស់សហមេធាវី ចំពោះបញ្ហានេះគឺជាការទាយស្មានទាំងស្រុង ដោយតម្រូវឱ្យអង្គបុរេជំនុំជម្រះ ធ្វើសមត្ថកម្មមិនត្រឹមតែចំពោះ លទ្ធផលនៃសំណុំរឿង ០០៤/២ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះដំណើរការទៅមុខនៃសំណុំរឿង ០០៣ ផងដែរ ក្រោយពេលដែលខ្លួន បានចេញសេចក្ដីសម្រេច[65]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងបន្ថែមថា ជាការខុសច្បាប់ក្នុងការសន្និដ្ឋានថា អង្គជំនុំជម្រះតុលាការកំពូល មិនមានយុត្តាធិការ ក្នុងការសម្រេចលើបញ្ហា ដោយផ្អែកលើមូលដ្ឋានដែលថា សេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង គឺមិនមែនជាសេចក្ដីសម្រេច អនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងនោះទេ[66]។ ជាកំហុសដូចគ្នាដែរនោះ បើតាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺសំណើរបស់សហមេធាវី ឱ្យមានការមូលមតិជា

[63] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៦។

[64] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៥, ១៧។

[65] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៨។

[66] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ១៩។

ឯកច្ឆន្ទ ក្នុងចំពោះចៅក្រមអង្គបុរេជំនុំជម្រះ ធ្វើសេចក្ដីសម្រេចរបស់ខ្លួន ក្នុងសំណុំរឿង ០០៣ ផ្អែកលើសកម្មភាពរបស់ អង្គជំនុំជម្រះផ្សេងទៀត ក្នុងសំណុំរឿងផ្សេងនោះ ព្រោះកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ទទួលស្គាល់ថា ការមូលមតិជាឯកច្ឆន្ទមិនមែនជាលក្ខខណ្ឌតម្រូវទេ និងអាចធ្វើមិនបានផងដែរ[67]។ សហព្រះរាជអាជ្ញាអន្តរជាតិបន្ថែមទៀតថា ការទទួលយកសារណាបន្ថែម ដែលរួមមានសំណើឲ្យមានសវនាការផ្ទាល់មាត់ គឺជាការប្រថុយប្រថាន បង្កើតឲ្យមានការពន្យាពេលយ៉ាងខ្លាំង ចំពោះការសម្រេចសេចក្ដីរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៣[68]។

24. ចំពោះអង្គសេចក្ដីវិញ ជាបឋម សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា អង្គបុរេជំនុំជម្រះមិនត្រូវបានតម្រូវឲ្យសម្រេចបដិសេធដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ ថាមោឃៈ និងឥតបានការនោះឡើយ[69]។ ដើម្បីគាំទ្រចំណុចនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា ផ្ទុយនឹងការអះអាងរបស់សហមេធាវី ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបានតម្រូវថាការសម្រេចរបស់អង្គបុរេជំនុំជម្រះ ទៅលើការចេញដោយខុសច្បាប់ នូវដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា របស់សហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០៤/២ នឹងបណ្ដាលឲ្យដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ ទៅជាមោឃៈ និងឥតបានការ ដោយស្វ័យប្រវត្តិនោះទេ ព្រោះចៅក្រមទាំងប្រាំរូបនៃអង្គជំនុំជម្រះ បានអនុវត្តនិងប្រើប្រាស់សិទ្ធិអំណាចត្រួតពិនិត្យពិសេស របស់អង្គបុរេជំនុំជម្រះ ក្នុងការស្ដារនីត្យានុកូលភាព និងការដោះស្រាយចំពោះកំហុសផ្នែកនីតិវិធី[70] ដោយដោះស្រាយលើផលប៉ះពាល់ នៃការសម្រេចរបស់ពួកគាត់ ចំពោះការចេញដីកាដំណោះស្រាយដាច់ពីគ្នា តាមមតិយោបល់ដាច់ដោយឡែករបស់ពួកគាត់[71] និងពិចារណាលើអង្គសេចក្ដី នៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពីការសម្រេចបែបនេះ[72]។ សហព្រះរាជអាជ្ញាអន្តរជាតិបាន

[67] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២០។

[68] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២១។

[69] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២២-២៦។

[70] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២២។

[71] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២២។

[72] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២២-២៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

អះអាងបន្ថែមថា ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបានតម្រូវថា ដីកាដំណោះស្រាយដែលមានវិការនីតិវិធី គួរត្រូវបានមោឃភាព និងដកចេញពីសំណុំរឿងឡើយ ព្រោះ (១) មិនមានចន្លោះប្រហោងនៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ដែលផ្អែកទៅលើអត្ថន័យសាមញ្ញរបស់វិធាននេះ និងវិធាននៃការបកស្រាយពាក់ព័ន្ធនានា គឺមិនអាចអនុវត្តបានឡើយ នៅក្នុងករណីមួយនេះ ដោយសារតែវិធាននេះគ្រប់ដណ្តប់តែទៅលើដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ និងខ្លឹមសាររបស់ដីកាសម្រេចនោះប៉ុណ្ណោះ គឺមិនមែនគ្រប់ដណ្តប់ទៅលើកាលៈទេសៈនៃការចេញដីកានោះឡើយ[73] ហើយ (២) នីតិវិធីមោឃភាព ដែលមានចែងនៅក្នុងវិធាន ៧៦ នៃវិធានផ្ទៃក្នុង ដូចដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់ មិនអនុវត្តចំពោះដីកាដំណោះស្រាយឡើយ ហើយវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង មិនបានរួមបញ្ចូល ការដាក់សំណើសុំមោឃភាព ក្រោយពេលចេញដីកាដំណោះស្រាយទេ ហើយសំណើសុំបែបនេះ អាចមិនត្រូវបានទទួលយក នៅពេលដែលដីកាដែលសំណើសុំនោះ មានបំណងចង់ធ្វើមោឃភាព គឺស្ថិតក្នុងកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង[74]។ ចំពោះបញ្ហានេះ សហព្រះរាជអាជ្ញាអន្តរជាតិបន្ថែមថា សហមេធាវីមានការយល់ច្រឡំ អំពីវិការនីតិវិធីដែលចោទឡើយ ជាមួយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ក្នុងការធ្វើមោឃភាពកិច្ចស៊ើបសួរ ក្រោយពេលដែលបានត្រួតពិនិត្យ ទៅលើសំណើសុំមោឃភាពដោយមានសំអាងហេតុ ហើយបានមើលរំលងវិធាន៤៨ នៃវិធានផ្ទៃក្នុង រួមទាំងយុត្តិសាស្ត្ររបស់ អង្គជំនុំជម្រះតុលាការកំពូល ដែលបង្ហាញថា ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនព្យាករឲករណ៍ទុកជាមុននូវ រាល់វិការៈនីតិវិធីទាំងអស់ នឹងនាំឲ្យសកម្មភាពមួយ ឬសេចក្តីសម្រេចជាលទ្ធផលទៅជាមោឃៈ *ពីពេលចាប់ផ្តើម* នោះទេ ប៉ុន្តែចំពោះតែកំហុសធ្ងន់នីតិវិធី ដែលបណ្តាលឲ្យមានលទ្ធផលដែលមានភាពអយុត្តិធម៌យ៉ាងធ្ងន់ធ្ងរ នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការប៉ុណ្ណោះ[75]។

25. ចំណុចទី២ សហព្រះរាជអាជ្ញាអន្តរជាតិបានសន្និដ្ឋានថា ការជាប់គាំងផ្នែកនីតិវិធីក្នុងសំណុំរឿង ០០៣ មិនមែនមិនអាចជៀសផុតនោះបាន[76]។ ដើម្បីគាំទ្រចំណុចនេះ លោកស្រីបានផ្តល់ទឡ្ហីករណ៍

[73] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៤។

[74] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៥។

[75] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៥។

[76] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៧-៣១។

តវ៉ាថា ទី១ ផ្ទុយពីការព្យាករណ៍គ្មានមូលដ្ឋានរបស់សហមេធាវី ការជាប់គាំងផ្នែកនីតិវិធីក្នុងសំណុំរឿង ០០៣ មែនមែនមិនអាចចៀសផុតនោះទេ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះពុំចាំបាច់តម្រូវឲ្យបញ្ជូនរឿងក្តីនេះទៅសហចៅក្រមស៊ើបអង្កេតវិញនោះឡើយ ឬ *ធ្វើការពិនិត្យសាជាថ្មីឡើងវិញ* ដោយខ្លួនឯងនោះទេ[77]។ ត្រង់ចំណុចនេះ លោកស្រីបានអះអាងថា មិនត្រឹមតែការអះអាងរបស់សហមេធាវី ស្តីពីការចាត់ទុកជាមោឃៈចំពោះដីកាដំណោះស្រាយដោយឡែកពីគ្នាក្នុងសំណុំរឿង ០០៤/២ មានកំហុសនោះឡើយ ការវិភាគរបស់សហមេធាវីអំពីផលប៉ះពាល់ជាក់ស្តែងនៃជម្រើសទាំងពីរនេះ គឺឃើញសុទ្ធតែមានការច្របាច់អង្គហេតុបញ្ចូលគ្នា[78]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងបន្ថែមទៀតថា យោងតាមកាតព្វកិច្ចរបស់អង្គបុរេជំនុំជម្រះក្នុងនោះរួមមានការការពារផលប្រយោជន៍របស់ជនត្រូវចោទ និងការទទួលយកដំណោះស្រាយសមស្រប ការអះអាងរបស់សហមេធាវីទាក់ទងនឹងអង្គជំនុំជម្រះ ដែលពុំមានលទ្ធភាពបំពេញកិច្ច ក្នុងពេលគ្មានការព្រមព្រៀងជាឯកច្ឆ័ន្ទដែលមានការធានានោះ គឺមានកំហុសជាមូលដ្ឋាន[79]។

26. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងបន្ថែមទៀតថា ពុំមានបន្សល់នូវភាពមិនប្រាកដប្រជាផ្នែកផ្លូវច្បាប់ដែលកើតចេញពីការពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ នោះឡើយ ដោយសារភាពមិនប្រាកដប្រជានោះត្រូវបានដកចេញ នៅពេលដែលអង្គជំនុំជម្រះពិចារណាលើអានុភាពផ្លូវច្បាប់នៃដីកាដំណោះស្រាយនីមួយៗ ក្រោយពេលខ្លួនបានសម្រេចលើការចេញដីកាដំណោះស្រាយពីរដោយខុសច្បាប់នោះ[80]។ លោកស្រីបានគូសបញ្ជាក់ជាថ្មីថា ប្រសិនបើពុំមានសម្លេងភាគច្រើនលើសលប់ យោងតាមសេចក្តីសម្រេចផ្នែកនយោបាយដែលបានបង្ហាញនៅក្នុងកិច្ចព្រមព្រៀងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ក៏ដូចជាការរកឃើញជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីពិចារណាលើសំណុំរឿង ០០៤/២ នោះសំណុំរឿង ០០៤/២ ត្រូវដំណើរការទៅជំនុំជម្រះដោយផ្អែកលើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដោយសារអង្គជំនុំជម្រះ

---

[77] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៧។

[78] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៧។

[79] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៧។

[80] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៨-៣១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

មិនបានឈានទៅរកសម្លេងភាគច្រើនលើសលប់ចាំបាច់ ឈានទៅបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ[81]។

27. ចំណុចចុងក្រោយ ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់លោកស្រីថា ការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ក្នុងសំណុំរឿង ០០៣ ពុំចាំបាច់នោះទេ[82] សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថាការលើកឡើងរបស់សហមេធាវីអំពីទ្រឹស្តីនៃការបំពានដំណើរការនីតិវិធី គឺជាការភាន់ច្រឡំពីព្រោះសហមេធាវី (i) បំភ្លៃយុត្តិសាស្ត្រ អ.វ.ត.ក ដែលទ្រឹស្តីនេះមិនដែលត្រូវបានអនុវត្តនោះទេដោយសារការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ដែលនាំឲ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធីជាស្ថាពរនោះ មិនអាចលើកឡើង លើកលែងតែក្នុងហេតុផលដូចមានចែងនៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[83]។ (២) ខកខានមិនបានបំពេញលក្ខខណ្ឌដ៏ខ្ពស់ ដែលបង្កើតឡើងដោយអង្គជំនុំជម្រះ នៃ អ.វ.ត.ក និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ចំពោះការផ្អាកជាអចិន្ត្រៃយ៍ ដោយផ្អែកលើការបំពានកិច្ចដំណើរការ[84]។ លោកស្រីបានបន្ថែមជាចុងក្រោយថា ដោយសារឧក្រិដ្ឋកម្ម ដែល មាស មុត ត្រូវបានចោទប្រកាន់ ដែលជាការព្រួយបារម្ភខ្លាំងបំផុតចំពោះសហគមន៍អន្តរជាតិ ដូច្នេះ ការផ្អាកជាអចិន្ត្រៃយ៍លើសំណុំរឿង ០០៣ នឹងមិនមានសមមាត្រយ៉ាងខ្លាំង[85]។ ដូច្នេះ ចំណុចនេះមានន័យថា សហមេធាវីខកខានមិនបានបង្ហាញថា ការផ្អាកកិច្ចដំណើរការនីតិវិធីជា

អចិន្ត្រៃយ៍ គឺជាឧបាស្រ័យដ៏សមរម្យតែមួយគត់ ដើម្បីដោះស្រាយការចោទប្រកាន់របស់ មាស មុត អំពីព្យសនកម្មចំពោះអត្ថិភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលពុំអាចតវ៉ាបាន ហើយកំពុងនៅតែទោលចំពោះរូបគាត់ជារៀងរហូត ដោយសារដំណោះស្រាយដ៏ជាក់ស្តែងបំផុតគឺគួរទទួលយក

---

[81] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២៨-២៩។

[82] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ៣២-៣៧។

[83] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ៣២-៣៣។

[84] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ៣២ កថាខណ្ឌ ៣៤-៣៥។

[85] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ៣៦-៣៧។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C C.E.T.C

ការសម្រេចចិត្តច្បាស់លាស់មួយនៅក្នុងវិធានផ្ទៃក្នុង កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ដើម្បីពន្លឿនសំណុំរឿងទៅជំនុំជម្រះ[86]។

28. នៅក្នុងចម្លើយតប សហមេធាវីបានបញ្ជាក់ជាថ្មីម្តងទៀតនូវអំណះអំណាងរបស់ខ្លួនអំពីភាពអាចទទួលបាននៅក្នុងសារណាបន្ថែម[87] និងបានបញ្ជាក់ថា សារណាបន្ថែមនេះគឺដើម្បីបំពេញបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដោយបានស្នើសុំឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ជាអចិន្ត្រៃយ៍ យោងតាមសេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង ដែលវាមិនមែនជាបណ្តឹងឧទ្ធរណ៍បន្ថែមនោះទេ ពីព្រោះសហព្រះរាជអាជ្ញាអន្តរជាតិបានលើកសេចក្តីសន្និដ្ឋានដោយនាំឱ្យមានការភាន់ច្រឡំ[88]។ សហមេធាវីអះអាងបន្ថែមទៀតថា ការទទួលយកសារណាបន្ថែម នឹងមិនបង្កហានិភ័យដល់ការពន្យាពេលយូរលើការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណុំរឿង ០០៣ នោះទេ ដោយសារអង្គជំនុំជម្រះបានទទួលសេចក្តីសន្និដ្ឋានពេញលេញនៅក្នុងចម្លើយតប ហើយសវនាការពុំអាចធ្វើឡើងបានឆាប់រហ័សតាមរយៈប្រព័ន្ធវីដេអូនោះឡើយ[89]។

29. ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ចាត់ទុកជាមោឃៈ[90] សហមេធាវីលើកឡើងនូវអំណះអំណាងរបស់ខ្លួនឡើងវិញនៅក្នុងសារណាបន្ថែម ពាក់ព័ន្ធនឹងវិធាន ៦៧ (២)[91] សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[92] និងការចង្អុលយោងលើឧទាហរណ៍នានានៅក្នុងសេចក្តីសម្រេចរបស់សាលាក្តី *មិនអចិន្ត្រៃយ៍* ដែលបានចេញ *ហួសដែនសមត្ថកិច្ច* និងរកឃើញថាមោឃៈ[93] ក៏ដូចជារបៀប ដែលក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក កំណត់ថា កិច្ចដែលមានវិការៈផ្នែកនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវមោឃៈ និងលុប

[86] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ៣៧។
[87] ចម្លើយតប (ឯកសារ D267/29) កថាខណ្ឌ ២-៤, ៦-១០។
[88] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១, ៥។
[89] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ៩។
[90] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១០-១៥។
[91] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១២។
[92] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១៤។
[93] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១៥។

ចេញពីក្នុងសំណុំរឿង[94]។ សហមេធាវីអះអាងបន្ថែមទៀតថា សេចក្តីសម្រេចដែលចងកាតព្វកិច្ចផ្លូវច្បាប់តែមួយគត់របស់អង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង ០០៤/២ គឺជាការរកឃើញជាឯកច្ឆន្ទអំពីការចេញដីកាដំណោះស្រាយដោយខុសច្បាប់[95] និងអង្គជំនុំជម្រះមិនបានអនុវត្តអំណាចឲ្យបានទូលំទូលាយក្នុងការពិនិត្យមើលសំណុំរឿងឡើងវិញ "ដើម្បីពោលប្រាស្រ័យទាំងអស់លើកិច្ចទាំងឡាយទាក់ទិននឹងរឿងក្តី ដែលអយ្យការ ឬ ចៅក្រមស៊ើបសួរ ឬ គួរបានធ្វើ ដើម្បីឲ្យការណែនាំនោះ មានលក្ខណៈពេញលេញ និងស្របច្បាប់"[96]។ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សារណាបន្ថែមអះអាងថា រាល់វិការៈផ្នែកនីតិវិធី នាំឲ្យដីកាដំណោះស្រាយមោឃៈ សហមេធាវីបានបញ្ជាក់ថា សារណាបន្ថែមនេះគ្រាន់តែអះអាងថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាដោយខុសច្បាប់ នាំឲ្យដីកាដំណោះស្រាយទាំងនោះមោឃៈ ដោយសារដីកាដំណោះស្រាយនោះត្រូវបានចេញដោយពុំមានការអនុញ្ញាតតាមផ្លូវច្បាប់[97]។

30. ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ចាំបាច់ត្រូវធ្វើឡើងនៅក្នុងសំណុំរឿង ០០៣ សហមេធាវីបានបញ្ជាក់ជាថ្មីម្តងទៀតថា ការជាប់គាំងផ្នែកនីតិវិធីក្នុងសំណុំរឿង ០០៣ នឹងពិចារណាដោយជៀសមិនរួចលើ (i) ការអះអាងផ្ទុយគ្នារបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ក្នុងសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនដីកាដំណោះស្រាយទៅសហចៅក្រមស៊ើបអង្កេត ឬ ពិនិត្យមើលសំណុំរឿងដោយខ្លួនឯងឡើងវិញ[98] និងនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួន អំពីការបញ្ចប់សំណុំរឿង ០០៤/០២ ជាស្ថាពររបស់អង្គជំនុំជម្រះ

---

[94] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១៤។

[95] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១០។ *យោងលើ* សំណុំរឿង ០០៤ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និងឯកសារ D360/33) កថាខណ្ឌ ៦១។

[96] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១១។

[97] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១៣។

[98] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១៦ *យោងលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ* (ឯកសារ D266/2) កថាខណ្ឌ ៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. ២១

សាលាដំបូងទាក់ទងនឹងការជាប់គាំងនីតិវិធីដែលជៀសមិនរួចនៅក្នុងសំណុំរឿង ០០៣[99] ហើយថា (ii) មិនមានសម្លេងភាគច្រើនលើសលប់ ដូចបានអះអាងដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ដែលអាចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញខុសច្បាប់ និងមានវិការៈផ្នែកនីតិវិធី[100]។ សហមេធាវីគូសបញ្ជាក់ជាថ្មីនូវអំណះអំណាងរបស់ខ្លួននៅក្នុងសារណាបន្ថែមទាក់ទងនឹងភាពអាចអនុវត្តបាន នៃទ្រឹស្តីអំពីការបំពានកិច្ចដំណើរការ[101] និងបានបញ្ជាក់ថា ខ្លួនបានយោងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះជាមូលដ្ឋានក្នុងការលើកឡើងថា អង្គជំនុំជម្រះ មាន ឬ អាចអនុវត្តឆន្ទានុសិទ្ធិ ក្នុងការលើកឡើងអំពីទ្រឹស្តីនៃការបំពានដំណើរការ មិនមែនថា អង្គជំនុំជម្រះពិតជាបានធ្វើដូច្នេះនៅក្នុងសេចក្តីសម្រេច ដែលបានលើកឡើងនោះទេ[102]។ សហមេធាវីសន្និដ្ឋានថា ដោយសារការជាប់គាំងផ្នែកនីតិវិធីក្នុងសំណុំរឿង ០០៣ ការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ គឺជាឧបាស្រ័យដ៏សមរម្យតែមួយគត់ ដើម្បីការពារការរំលោភបំពានធ្ងន់ធ្ងរដ៏អាក្រក់លើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ របស់ មាស មុត[103]។

## III. ការពិភាក្សា

31. អង្គបុរេជំនុំជម្រះ បានទទួលប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរនៅក្នុងសំណុំរឿង ០០៣[104]។ កិច្ចដំណើរការនីតិវិធីក្នុងរឿងក្តីនេះ ត្រូវបានបិទបញ្ចប់ ហើយអង្គបុរេជំនុំជម្រះពិនិត្យអំណះអំណាងរបស់ភាគី និងពិភាក្សាលើបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង។

---

[99] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១៧ *យោងលើបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង ០០៤/០២*(ឯកសារ E004/2/1) កថាខណ្ឌ ៤៨។

[100] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ១៩។

[101] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ២០។

[102] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ២១។

[103] ការឆ្លើយតប (ឯកសារ D267/31) កថាខណ្ឌ ២២-២៥។

[104] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3)។ បណ្តឹងឧទ្ធរណ៍របស់ មាស មុត (ឯកសារ D267/4)។ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C. ២២

32. អង្គបុរេជំនុំជម្រះពិចារណាឃើញថា សេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង ដែលជាឯកសារមានអានុភាពតាមផ្លូវតុលាការ នៅក្នុងដំណើរការនីតិវិធីផ្សេង មិនមានអានុភាពភ្លាមៗ ឬដោយផ្ទាល់លើសំណុំរឿងដែលកំពុងសម្រេចសេចក្តីនោះឡើយ។

33. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍នានា នៅក្នុងរឿងក្តីនេះ ត្រូវបានសង្ខេបជូនយ៉ាងលម្អិត តាមរយៈសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងការជជែកដេញដោលផ្ទាល់មាត់ដោយភាគីនានាក្នុងអំឡុងពេលសវនាការរយៈពេលបីថ្ងៃរួចហើយ[105]។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ អនុលោមតាមវិធាន ២១ ត្រូវបានការពារយ៉ាងត្រឹមត្រូវ។

34. ទាក់ទងនឹងអំណះអំណាង ដែលបានលើកឡើងនៅក្នុងសារណាបន្ថែមដែលថា អង្គបុរេជំនុំជម្រះចាំបាច់ត្រូវយកអំណាចរបស់ខ្លួន មកប្រើប្រាស់ដើម្បីកំណត់បញ្ហា ដែលកើតឡើងចំពោះរឿងក្តីបច្ចុប្បន្ននេះ ដោយពិចារណាទៅដល់ការការពារដំណើរការស្វែងរកយុត្តិធម៌ដ៏ល្អ និងត្រឹមត្រូវ[106] អង្គបុរេជំនុំជម្រះ ក្នុងពេលដែលអះអាងបញ្ជាក់ឡើងវិញអំពីលទ្ធភាពរបស់ខ្លួនក្នុងការប្រើអំណាចបែបនេះ[107] យល់ឃើញថា កាលៈទេសៈនៅក្នុងរឿងក្តីបច្ចុប្បន្ន ក្នុងខណៈដែលអង្គជំនុំជម្រះនៃ អ.វ

---

[105] សំណុំរឿង ០០៣ ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ D266/12។

[106] សារណាបន្ថែម (ឯកសារ D267/27) កថាខណ្ឌ ៣។

[107] *ឧទា. សូមមើល* សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ (ឯកសារ D359/24 និងឯកសារ D360/33) កថាខណ្ឌ ៣២។ សំណុំរឿង ០០២ (អ.ប.ជ ៧៣) សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ១០៦, ១១៥។ សំណុំរឿង ០០២ (អ.ប.ជ ០៣) សេចក្តីសម្រេចលើពាក្យសុំពិចារណាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ C22/I/68 កថាខណ្ឌ ២៥-២៦។ សំណុំរឿង ០០៣ (អ.ប.ជ ០៣) ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្តីពីដីកាថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងទៅនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D14/1/2 កថាខណ្ឌ ៤-៥។ សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D360/3 កថាខណ្ឌ ៦-៧, ១២។ សំណុំរឿង ០០៣ (អ.ប.ជ ១១) សេចក្តីសម្រេចលើសំណើសុំឲ្យមានវិធានការបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ D56/19/8 កថាខណ្ឌ ១៥-១៦។

.ត.ក មួយ មានសមត្ថកិច្ច នៅដំណាក់កាលជំនុំជម្រះ បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ក្នុងករណីមួយផ្សេងទៀតនោះ មិនតម្រូវឲ្យយកអំណាចនោះមកអនុវត្តនោះឡើយ។

35. អង្គបុរេជំនុំជម្រះយល់ឃើញថា តាមពិតទៅ សារណាបន្ថែមកំពុងស្នើសុំឲ្យមានការសម្រេចសេចក្តីស្តាពរពីអង្គជំនុំជម្រះ នៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះ ដែលនឹងត្រូវចេញក្នុងពេលវេលាមួយសមស្រប។ ពុំមានមូលហេតុណាមួយដែលតម្រូវឲ្យអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចឆាប់រហ័សពេក ទៅលើបញ្ហាដែលស្ថិតក្នុងវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ដែលកំពុងដំណើរការនោះទេ។

36. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សារណាបន្ថែមមិនអាចទទួលយកបាន។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បដិសេធ** មិនទទួលយកសារណាបន្ថែម។

**បដិសេធ** សំណើរបស់សហមេធាវីក្នុងការស្នើសុំសវនាការទាំងមូល។

យោងតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២០**

**ប្រធាន**

**អង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន Olivier BEAUVALLET ន័យ ផុល Kang Jin BAIK ហួត វុទ្ធី